

# មួយពាក្យម្តងៗ

## ដៃគូណែនាំសម្រាប់សិក្សាព្រះគម្ពីរ

លីនហ្ស៊ី ម៉ាឡុន

សំបុត្រផ្ដើម៖

មកដល់មិត្តភក្តិជាទីស្រឡាញ់!

ខ្ញុំដឹងថា វាជាការគួរឲ្យព្រួយបារម្ភក្នុងការសិក្សាឲ្យបានស៊ីជម្រៅនៅក្នុងព្រះគម្ពីរដោយខ្លួនឯងផ្ទាល់ ហើយអាចមានអារម្មណ៍ថាដូចជាមិនអាចយល់បានការពិតដ៏ស៊ីជម្រៅមួយចំនួនដូចដែលគ្រូបង្រៀនព្រះគម្ពីរដែលមានជំនាញចែកចាយនោះទេ។ មិនមែនយើងមិនអាចរៀនបានដោយការស្ដាប់ឮពីការរៀនសូត្ររបស់អ្នកដទៃនោះទេ ប៉ុន្តែក្តីសង្ឃឹមរបស់ខ្ញុំគឺថា នៅពេលដែលលោកអ្នករីកចម្រើនក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយព្រះយេស៊ូវ នោះលោកអ្នកក៏អាចត្រៀមខ្លួនរួចជាស្រេចក្នុងការដែលនឹងសិក្សាស្វែងយល់ឲ្យបានស៊ីជម្រៅពីព្រះហឫទ័យដ៏ល្អរបស់ព្រះវរបិតានៃយើងផងដែរ។ ការសិក្សាព្រះបន្ទូលរបស់ព្រះគឺជាឯកសិទ្ធិដ៏អស្ចារ្យមួយពោលគឺវាជាការអស្ចារ្យដែលព្រះនៃរបស់សព្វសារពើបានជ្រើសក្នុងការបើកសម្ដែងអង្គទ្រង់ឲ្យយើងឃើញតាមរយៈព្រះបន្ទូលទ្រង់ដែលបានចែងទុក។ តាមរយៈការធ្វើដូច្នេះ ទ្រង់បានបើកសម្ដែងប្រាប់យើងថាព្រះហឫទ័យរបស់ទ្រង់គឺចង់នៅក្បែរប្រជារាស្ត្ររបស់ទ្រង់។

គោលបំណងរបស់ខ្ញុំគឺចង់ជួយឲ្យលោកអ្នកត្រៀមខ្លួនជាស្រេចក្នុងការសិក្សាព្រះបន្ទូលទ្រង់កាន់តែប្រសើរឡើង ដើម្បីឲ្យលោកអ្នកអាចចូលកាន់តែជិតស្និទ្ធិទៅកាន់ «ព្រះវរបិតា (អ័ប្បា)» ដែលមានព្រះទ័យទុកដាក់ចំពោះព្រលឹងវិញ្ញាណរបស់លោកអ្នកយ៉ាងខ្លាំង គឺដែលទ្រង់ចាត់ព្រះរាជបុត្រាទ្រង់តែមួយឲ្យយាងមកសុគត និងរស់ឡើងវិញ គឺដើម្បីឲ្យយើងបានចូលទៅជិតព្រះវត្តមានទ្រង់។

ខ្ញុំអធិស្ឋានសូមឲ្យការណែនាំដ៏តូចមួយនេះអាចជួយលោកអ្នកក្នុងការសិក្សាអត្ថបទព្រះបន្ទូលបានយ៉ាងល្អ។

សូមឲ្យព្រះគុណរបស់ព្រះមានដល់លោកអ្នកជាបរិបូរ!

លីនហ៊ុី



# អធិស្ឋាន

មុនពេលលោកអ្នកចាប់ផ្តើមសិក្សាកណ្ឌព្រះគម្ពីរណាមួយ សូមចាប់ផ្តើមជាមួយការអធិស្ឋាន។ បើមិនមានព្រះវិញ្ញាណបរិសុទ្ធបើកភ្នែក និងដួងចិត្តរបស់យើងទេ នោះគ្រប់ទាំងព្រះបន្ទូលអាចមិនឮដល់យើងទេ។

ព្រះវិញ្ញាណបរិសុទ្ធជួយយើងក្នុងការកាត់ស្រាយ យល់ និងមានអំណរចំពោះសេចក្តីពិតដ៏ស្រស់ស្អាតនៅក្នុងព្រះបន្ទូលរបស់ព្រះ ដូច្នេះគឺដើម្បីឲ្យយើងបានផ្លាស់ប្រែដោយសេចក្តីពិតទាំងនោះ។



# អានហើយ អានទៀត

មុនពេលចូលសិក្សាឲ្យបានស៊ីជម្រៅនៅក្នុងអត្ថបទព្រះគម្ពីរ សូមអានដោយចាប់ផ្តើមពីដំបូងរហូតដល់ចប់យ៉ាងហោចណាស់ឲ្យបានមួយដង។ ខ្ញុំសូមលើកទឹកចិត្តឲ្យអានបទគម្ពីរនោះទាំងមូលរាល់ពេលដែលលោកអ្នកអង្គុយចុះ ដើម្បីសិក្សាផ្នែកថ្មីរបស់អត្ថបទនោះ។ ដូចដែលលោកអ្នកបានអានជាប្រចាំ ការអានម្តងហើយម្តងទៀតនេះនឹងជួយលោកអ្នកឲ្យអានកាន់តែមានភាពស៊ាំនឹងបទគម្ពីរ ព្រមទាំងផ្តល់គំនិតថ្មីៗ ប្រធានបទថ្មីៗ និងពាក្យពេចន៍ថ្មីៗជាដើម។



លោកអ្នកអាចចូលទៅស្តាប់អត្ថបទព្រះគម្ពីរនេះបានតាមរយៈកម្មវិធី *"YouVersion"* នៅលើទូរស័ព្ទរបស់លោកអ្នកផងដែរ![3]



# ការសិក្សាឲ្យស៊ីជម្រៅ

សូមចាប់ផ្តើមជាមួយពត៌មាននៃប្រវត្តិរបស់សៀវភៅដែលលោកអ្នកសិក្សា។ ក្នុងការប្រមូលផ្នែកគន្លឹះមួយនៃពត៌មាន ចំណុចទាំងនេះនឹងជួយកំណត់អំពីរបៀបដែលលោកអ្នកអាន និងយល់អំពីបទគម្ពីរ។.



# អ្នកនិពន្ធ

- តើអ្នកណាជាអ្នកនិពន្ធកណ្ឌគម្ពីរនេះ?
- តើលោកអ្នកស្គាល់អំពីអ្នកនិពន្ធយ៉ាងដូចម្តេច ចេញពីបទគម្ពីរជាក់លាក់នេះ?
- តើលោកអ្នករកឃើញព័ត៌មានផ្សេងទៀតរបស់អ្នកនិពន្ធនៅផ្នែកណាក្នុងព្រះគម្ពីរ?

ជំនួយ៖ លោកអ្នកអាចប្រើព្រះគម្ពីរសម្រាប់សិក្សា ឬសៀវភៅអត្ថាធិប្បាយព្រះគម្ពីរសម្រាប់ការនេះ។

- តើការដឹងអំពីព័ត៌មានរបស់អ្នកនិពន្ធនេះ មានឥទ្ធិពលយ៉ាងដូចម្តេចចំពោះការអានព្រះគម្ពីររបស់លោកអ្នក?

# អ្នកអាន

- តើកណ្ឌគម្ពីរនេះសរសេរទៅកាន់អ្នកណា ឬសម្រាប់អ្នកណា?
- តើលោកអ្នកអាចស្គាល់អំពីអ្នកអានយ៉ាងដូចម្ដេច ចេញពីបទគម្ពីរជាក់លាក់នេះ?



- តើលោកអ្នករកឃើញព័ត៌មានផ្សេងទៀតរបស់អ្នកអាននៅកន្លែងណាក្នុងព្រះគម្ពីរ?
- តើអ្នកអានបានអានបទគម្ពីរនេះដោយរបៀបណា?
- តើការដឹងអំពីព័ត៌មានរបស់អ្នកអាននេះ មានឥទ្ធិពលយ៉ាងដូចម្ដេចចំពោះការអានព្រះគម្ពីររបស់លោកអ្នក?





# កាលបរិច្ឆេទ

- តើកណ្ឌគម្ពីរនេះសរសេរឡើងនៅឆ្នាំណា?
- តើអ្នកអានកំពុងរង់ចាំកិច្ចការដែលនឹងមកដល់របស់ឈើឆ្កាង ឬកំពុងតែអនុវត្តតាមឈើឆ្កាងនោះ?

# គោលបំណង



- តើអ្វីជាគោលបំណងរបស់អ្នកនិពន្ធក្នុងការសរសេរបទគម្ពីរមួយនេះសម្រាប់អ្នកអានរបស់គាត់? តើគាត់កំពុងចង់មានការប្រាស្រ័យទាក់ទងអ្វីជាមួយពួកគេ?
- តើការដឹងគោលបំណងបែបនេះ មានឥទ្ធិពលយ៉ាងដូចម្ដេចចំពោះការអានព្រះគម្ពីររបស់លោកអ្នក?

# ប្រភេទ

- តើកណ្ឌគម្ពីរនេះជាកណ្ឌគម្ពីរប្រភេទណា?
- នៅក្នុងប្រភេទនេះ តើមានលក្ខណៈអ្វីខ្លះដែលលោកអ្នកធ្លាប់ស្គាល់?
- តើការដឹងអំពីប្រភេទបែបនេះ មានឥទ្ធិពលយ៉ាងដូចម្ដេចចំពោះការអានព្រះគម្ពីររបស់លោកអ្នក?



# ប្រភេទនៃអក្សរសិល្ប៍ក្នុងព្រះគម្ពីរ និងគន្លឹះសម្រាប់ការសិក្សា[5]

## និទានកថាប្រវត្តិសាស្ត្រ៖

លោកុប្បត្តិ
និក្ខមនំ
ជនគណនា
យ៉ូស្វេ
ពួកចៅហ្វាយ
នាងរស់
១សាំយ៉ូអែល
២សាំយ៉ូអែល
១ពង្សាវតាក្សត្រ
២ពង្សាវតាក្សត្រ
១របាក្សត្រ
២របាក្សត្រ
អែសរ៉ា
នេហេមា
នាងអេសធើរ
ដានីយ៉ែល ១-៦
ម៉ាថាយ
ម៉ាកុស
លូកា
យ៉ូហាន
កិច្ចការ



### គន្លឹះក្នុងការសិក្សា៖

ចូរស្វែងរកប្រធានបទ និងគំនិតសំខាន់ដែលចង្អុលបង្ហាញអំពីលក្ខណៈសម្បត្តិរបស់ព្រះ ជាជាងអនុវត្តផ្ទាល់ខ្លួនភ្លាមៗ។

## ក្រឹត្យវិន័យ៖

ច្បាប់បញ្ញត្តិសម្រាប់បណ្ដាជន៖
និក្ខមនំ ២០-២៣
ជនគណនា ៥-៦, ១៥, ២៨-៣០

ច្បាប់បញ្ញត្តិសម្រាប់ដាក់ទណ្ឌកម្ម៖
លេវីវិន័យ

ច្បាប់ក្រមរដ្ឋធម្មនុញ្ញ៖
ចោទិយកថា



### សំណួរដែលត្រូវសួរ៖

«តើសេចក្ដីបង្គាប់ ឬបញ្ញត្តិនីមួយៗប្រាប់ខ្ញុំអំពីលក្ខណៈរបស់ព្រះថា ទ្រង់ជាអ្នកណាយ៉ាងដូចម្ដេច?

## អក្សរសិល្ប៍ប្រាជ្ញា

**ប្រាជ្ញារបស់ស្ដេច សាឡូម៉ូន៖**
សុភាសិត៖ «តើខ្ញុំអាចមានប្រាជ្ញាដោយរបៀបណា?»
សាស្ដា៖ «តើអ្វីជាអត្ថន័យនៃជីវិត?»

**កំណាព្យនៃប្រាជ្ញា៖**
ទំនុកតម្កើង៖ «តើខ្ញុំអាចដាក់សេចក្ដីអំណរ និងទុក្ខព្រួយរបស់ខ្ញុំនៅឯណា»?
បទចម្រៀងសាឡូម៉ូន៖ «តើខ្ញុំអាចមានទស្សនៈចំពោះផ្លូវភេទយ៉ាងដូចម្ដេច?»
បរិទេវ៖ «តើខ្ញុំអាចចូលទៅកាន់ព្រះជាមួយការឈឺចាប់របស់ខ្ញុំបានដែរឬទេ?»

**និទានកថាបែបប្រាជ្ញា៖**
យ៉ូប៖ «តើព្រះមានសិទ្ធិលើជីវិតរបស់ខ្ញុំដែរឬទេ?»

# បទទំនាយ៖

**ហោរាតូច៖**
ហូសេ
យ៉ូអែល
អេម៉ុស
អូបាឌា
យ៉ូណាស
មីកា
ណាហ៊ុម
ហាបាគុក
សេផានា
ហាកាយ
សាការី
ម៉ាឡាគី

**ហោរាធំ៖**
អេសាយ
យេរេមា
អេសេគាល
ដានីយ៉ែល ៧-១២

**បទទំនាយផ្សេងទៀត៖**
វិវរណៈ



ចំណុចទាំង៣ស្រទាប់ដែលត្រូវមើល៖
**ស្រទាប់ទី១៖ បរិបទប្រវត្តិសាស្ត្រ**
**ស្រទាប់ទី២៖ ការអនុវត្តបច្ចុប្បន្ន**
**ស្រទាប់ទី៣៖ ព្រឹត្តិការណ៍អនាគត**

## សំបុត្រ

រ៉ូម
១កូរិនថូស
២កូរិនថូស
កាឡាទី
អេភេសូរ
ភីលីព
កូឡុស
១ថែស្សាឡូនីច
២ថែស្សាឡូនីច
១ធីម៉ូថេ
២ធីម៉ូថេ
ទីតុស
ភីលេម៉ូន
ហេព្រើរ
យ៉ាកុប
១ពេត្រុស
២ពេត្រុស
១យ៉ូហាន
២យ៉ូហាន
៣យ៉ូហាន
យូដាស



### ការអានសំបុត្រ៖

សូមចងចាំថា លោកអ្នកកំពុងអានការឆ្លើយឆ្លងរបស់អ្នកផ្សេង ហើយលោកអ្នកបានអានតែពាក់កណ្ដាលតែប៉ុណ្ណោះ។ សូមចាប់ផ្ដើមជាមួយសំណួរមូលដ្ឋានដូចជា៖ តើអ្នកណាជាអ្នកសរសេរ? ទៅកាន់អ្នកណា? នៅពេលណា? នៅកន្លែងណា? ហើយក្នុងគោលបំណងអ្វី?

# បរិបទ

- តើមានហេតុការណ៍ប្រវត្តិសាស្ត្រសំខាន់ណាខ្លះដែលបានកើតឡើងអំឡុងពេលនោះ ដែលអាចជះឥទ្ធិពលលើរបៀបនៃការអានព្រះគម្ពីររបស់លោកអ្នក?

ជំនួយ៖ សូមគិតទាំងប្រវត្តិសាស្ត្រនៃប្រជារាស្ត្រដែលព្រះបានជ្រើសរើស [សាសន៍អ៊ីស្រាអែល សាសន៍ហេព្រើរ សាសន៍យូដា] ក៏ដូចជាប្រវត្តិសាស្ត្រពិភពលោកផងដែរ។

- តើលោកអ្នកបានដឹងអ្វីខ្លះអំពីវប្បធម៌របស់អ្នកអាននៅអំឡុងពេលនោះ?
- តើបរិបទនៃប្រវត្តិសាស្ត្រនេះ មានឥទ្ធិពលយ៉ាងដូចម្ដេចចំពោះការអានព្រះគម្ពីររបស់លោកអ្នក?
- តើកណ្ឌគម្ពីរនេះមានទំនាក់ទំនងស៊ីគ្នាជាមួយនឹងដំណើរសាច់រឿងធំនៅក្នុងព្រះគម្ពីរយ៉ាងដូចម្ដេច?
- តើមានអំណះអំណាងអ្វី ឬការនិយាយដោយប្រយោលអ្វី ឬការភ្ជាប់អ្វី ទៅកាន់បទគម្ពីរផ្សេងទៀតដែលអ្នកនិពន្ធបានលើកឡើង?
- នៅក្នុងបទគម្ពីរនេះ តើលោកអ្នកឃើញមាននិយាយអំពីប្រធានបទទេវវិទ្យាអ្វីខ្លះ?

«រូបភាពធំនៃដំណើររឿង» ដែលមានក្នុងគ្រប់ទាំងបទគម្ពីរទាំងអស់ គឺ ផែនការរបស់ព្រះក្នុងការសង្គ្រោះប្រជារាស្ត្ររបស់ព្រះអង្គ!

សូមគិតអំពីប្រធានបទទុកដូចជា «ខ្សែ» ដែលមានដំណើរដើមទងពេញបទគម្ពីរទាំងមូល។



# ឧទាហរណ៍អំពីប្រធានបទក្នុងព្រះគម្ពីរ

| | |
|---|---|
| ព្រះពរ & បណ្តាសា | នំប៉័ង |
| បានស្អាត & មិនស្អាត | សម្លៀកបំពាក់ |
| ការតាំងសញ្ញា | ការចាកចេញពីអេហ្ស៊ីប & ការនិរទេស |
| ពិធីជប់លៀង | សួនច្បារអេដែន & ទីរហោស្ថាន |
| អេម៉ាញូអែល | នគរ |
| ពន្លឺ & សេចក្ដីងងឹត | អាពាហ៍ពិពាហ៍ |
| ពូជពង្ស & អ្នកបន្តពូជពង្ស | ភាពជាសង្ឃ |
| **ទឹកដីសន្យា** | យញ្ញបូជា |
| ព្រះវិហារ & រោងឧបោសថ | ថ្វាយបង្គំ |

# តើអ្វីជាដំណើរសាច់រឿងធំក្នុងព្រះគម្ពីរ?

## ការបង្កើត៖



ព្រះបានបង្កើតគ្រប់របស់ទាំងអស់ ហើយទាំងអស់ជាការល្អប្រពៃ។ មនុស្សមានទំនាក់ទំនងដ៏ល្អឥតខ្ចោះជាមួយព្រះអង្គ។

## ការធ្លាក់ចុះ៖

លោក អ័ដាម និងនាង អេវ៉ា បានធ្វើបាបដោយបរិភោគពីផ្លែដឹងខុសត្រូវ ដូច្នេះអ្វីទាំងអស់ដែលព្រះបានបង្កើតបានខូចដោយសារអំពើបាបដើម។ មនុស្សទាំងអស់បានដាច់ចេញពីទំនាក់ទំនងជាមួយព្រះ។



## ការប្រោសលោះ៖



ព្រះបានចាត់ព្រះរាជបុត្រារបស់ព្រះអង្គគឺ ព្រះយេស៊ូវ មកក្នុងលោកីយ៍ក្នុងភាពជាមនុស្ស ដើម្បីរស់នៅក្នុងជីវិតមួយដែលល្អឥតខ្ចោះ និងបរិសុទ្ធ ព្រមទាំងសុគតនៅលើឈើឆ្កាងសម្រាប់ជាថ្លៃធួនអំពើបាបនៃរាស្ត្ររបស់ព្រះអង្គ ហើយមានព្រះជន្មរស់ឡើងវិញ ដោយទ្រង់បានបង្កើតផ្លូវមួយឲ្យមនុស្សអាចមានទំនាក់ទំនងយ៉ាងត្រឹមត្រូវជាមួយនឹងព្រះម្តងទៀត។

## ការស្តារឡើងវិញ៖

ព្រះគ្រីស្ទនឹងត្រឡប់មកវិញក្នុងភាពជាស្តេច និងគ្រប់ការបង្កើតទាំងអស់នឹងទទួលស្គាល់ព្រះអង្គដូច្នោះដែរ! ព្រះនឹងស្តារអ្វីទាំងអស់ដែលទ្រង់បានបង្កើតឡើងវិញ ហើយរាស្ត្ររបស់ព្រះអង្គទាំងអស់នឹងមានទំនាក់ទំនងជាមួយព្រះអង្គល្អឥតខ្ចោះ។



# រចនាសម្ព័ន្ធ

រចនាសម្ព័ន្ធនៅក្នុងអត្ថបទបង្ហាញយើងអំពីអ្វីដែលអ្នកនិពន្ធកំពុងតែសង្កត់ធ្ងន់ ដែលមានឥទ្ធិពលលើការយល់ដឹង និងទំនាក់ទំនងនៃអត្ថបទ។

ប្រភេទនៃបទគម្ពីរខុសគ្នានឹងបង្ហាញអំពីរចនាសម្ព័ន្ធខុសគ្នាដែរ! ឧទាហរណ៍៖ បទគម្ពីរបែបនិទានកថានឹងមាន «គ្រោងនៃដំណើររឿង» (កាលអាកាស ការកើតមានជម្លោះ ដំណើររឿងធំជាងគេ ដំណោះស្រាយ និងកាលអាកាសថ្មី) តួអង្គជាដើម។ លោកអ្នកក៏ទំនងជាកត់សម្គាល់ដែរថា មានចំណុចច្រើនជាងគ្រោងនៃដំណើររឿងនេះទៅទៀត! រចនាសម្ព័ន្ធសម្រាប់ប្រភេទសុន្ទរកថាវិញ នឹងត្រូវបានបង្ហាញជាចម្បងតាមរយៈវេយ្យាករណ៍ អំណះអំណាង ពាក្យគន្លឹះ និងឃ្លាប់ឃ្លាជាដើម។ ហើយសម្រាប់រចនាសម្ព័ន្ធប្រភេទជាកំណាព្យវិញ នឹងត្រូវបានបង្ហាញតាមរយៈឃ្លា ចំណុចផ្ទួនៗ រូបភាពនៃដំណើររឿង ការផ្លាស់ប្តូរការនិយាយរបស់តួអង្គជាដើម។

របៀបមួយក្នុងការបំបែករចនាសម្ព័ន្ធនៃបទគម្ពីរគឺជាការសរសេរចេញជា «ប្លង់មេកានិច» ( Mechanical Layout) (ដែលនោះគឺជាគំនូសតាងពីឃ្លាមួយទៅឃ្លាមួយនៃបទគម្ពីរ ដើម្បីបង្ហាញអំពីទំនាក់ទំនងនៃវេយ្យាករណ៍ បង្ហាញអំពីលំហូរនៃការគិតតាមរូបភាព) បន្ទាប់មកចាប់ផ្តើម «**គូសចំណាំ**» បទគម្ពីរជាមួយប៊ិកពណ៌ ខ្មៅដៃ ហ្វឺតគូសចំណាំ... អ្វីក៏ដោយដែលលោកអ្នកអាចប្រើបានក្នុងការចងក្រងបញ្ជីដែលវាជាជំនួយដ៏មានប្រយោជន៍មួយសម្រាប់ទំព័របន្ទាប់!

មនុស្សមួយចំនួនបានរំលងចំណុច «ប្លង់មេកានិច» ហើយចាប់ផ្តើមដោយមើលលើចំណុច «គូស» តែម្តង ឬលោកអ្នកអាចធ្វើមួយណាដែលមាន [1] ប្រសិទ្ធភាពសម្រាប់លោកអ្នកបាន!





# វិធីសាស្ត្រសម្រាប់ រចនាសម្ព័ន្ធ



- ចំណុចផ្ទួន—សូមស្វែងរកពាក្យ និងឃ្លាផ្ទួន។
- ចំណុចផ្ទុយ—សូមស្វែងរកគំនិត បុគ្គល និង/ឬ របស់អ្វីដែលមានភាពផ្ទុយគ្នា។ សូមស្វែងរកចំណុចខុសគ្នា។
- ចំណុចប្រៀបធៀប—សូមស្វែងរកគំនិត បុគ្គល និង/ឬ របស់អ្វីដែលបានប្រៀបធៀបជាមួយគ្នា។ សូមស្វែងរកចំណុចស្រដៀងគ្នា។
- បញ្ជី—សូមកត់ចំណាំកន្លែងដែលបទគម្ពីរបានលើកឡើងអំពីរបស់អ្វីមួយលើសពីពីរដង។
- បុព្វហេតុ និងលទ្ធផល—អាចនឹងមានលទ្ធផលច្រើនជាងមួយដងកើតចេញពីបុព្វហេតុតែមួយដែលបានលើកឡើងនៅក្នុងបទគម្ពីរ។
- បំរៀបន័យ—សូមស្វែងរកការបង្ហាញដែលផ្តល់ព័ត៌មានឲ្យដឹងអំពីរូបភាព ដោយប្រើពាក្យក្នុងន័យផ្សេងក្រៅពីន័យត្រង់។



- ឈ្នាប់—សូមកត់សម្គាល់កន្លែងឃ្លាដែលភ្ជាប់គ្នាដូចជា «និង» «ប៉ុន្តែ» «ដ្បិត»។ សូមកត់សម្គាល់ថា ពាក្យទាំងនោះកំពុងភ្ជាប់ជាមួយឃ្លាអ្វីផ្សេងទៀត។
- កិរិយាស័ព្ទ—សូមកត់ចំណាំថា កិរិយាស័ព្ទនោះស្ថិតក្នុង អតីតកាល បច្ចុប្បន្នកាល ឬ អនាគតកាល កិរិយាសកម្ម ឬកិរិយាអកម្ម។ សូមរកមើលការបង្គាប់បញ្ជាផងដែរ។
- សព្វនាម—សូមកំណត់បុព្វបទសម្រាប់សព្វនាមនីមួយៗ។
- សំណួរ និងចម្លើយ—សូមកត់ចំណាំមើលថា តើបទគម្ពីរចាប់ផ្តើមសរសេរដោយទម្រង់ «សំណួរ—ចម្លើយ» ឬយ៉ាងណា។
- ការសន្ទនា—សូមកត់ចំណាំមើលថា តើបទគម្ពីរមានរួមបញ្ចូលការសន្ទនារបស់តួអង្គដែរឬទេ។ សូមរកកំណត់ថា តើអ្នកណាកំពុងនិយាយទៅកាន់អ្នកណា។
- មធ្យោបាយ—សូមកត់ចំណាំមើលថា ប្រសិនបើប្រយោគបានបង្ហាញពីអ្វីមួយដែលបានធ្វើហើយដោយ នរណាម្នាក់/អ្វីមួយ (ចម្លើយ «ដោយរបៀបណា?»)។ ជាធម្មតា លោកអ្នកអាចបញ្ចូលឃ្លា «ដោយមធ្យោបាយ» ទៅក្នុងប្រយោគបាន។
- លំដាប់លំដោយ—តើបទគម្ពីរមានការរៀបចំជាលំដាប់លំដោយដូចជា A-B-C-D-C’-B’-A’ ដែរឬទេ?

- គោលបំណង/ឃ្លានៃលទ្ធផល—ទាំងនេះគឺជាប្រភេទជាក់លាក់នៃ «មធ្យោបាយ» ដែលជារឿយៗ គឺប្រាប់អំពីមូលហេតុ។ គោលបំណង និងលទ្ធផល គឺមានភាពស្រដៀងគ្នាណាស់ ហើយពេលខ្លះ មិនអាចបែងចែកថា មួយណានោះទេ។ នៅក្នុងឃ្លាគោលបំណង ជាធម្មតា លោកអ្នកអាចដាក់បញ្ចូលឃ្លា «ដើម្បីឲ្យ» បាន។ ហើយនៅក្នុងឃ្លានៃលទ្ធផល ជាធម្មតាលោកអ្នកអាចដាក់បញ្ចូលឃ្លា «ដូច្នោះ» បាន។



- ពីទូទៅ ទៅជាក់លាក់ ពីជាក់លាក់ ទៅទូទៅ—សូមស្វែងរកឃ្លាទូទៅដែលអាចធ្វើតាមដោយឧទាហរណ៍ជាក់លាក់ ឬការអនុវត្តទូទៅ។ ហើយសូមស្វែងរកឃ្លាជាក់លាក់ដែលអាចសង្ខេបបានដោយឃ្លាទូទៅមួយផងដែរ។
- ឃ្លាតាមលក្ខខណ្ឌ—ឃ្លាអាចបង្ហាញអំពីលក្ខខណ្ឌដែលសកម្មភាពមួយចំនួន ឬលទ្ធផលមួយចំនួនដែលនឹងកើតឡើង។ ជាញឹកញាប់ ប្រយោគដូចនោះប្រើពាក្យដូចជា «ប្រសិនបើ...បន្ទាប់មក» ទោះបីជាពាក្យ «បន្ទាប់មក» ជាពាក្យសម្រាប់រចនាលម្អ (ជាញឹកញាប់ត្រូវបានទុកចោល ដោយគ្រាន់តែបង្កប់ន័យក៏ដោយ)។
- សកម្មភាព/តួនាទីរបស់ព្រះ—កំណត់អំពីសកម្មភាព ឬតួនាទីដែលបទគម្ពីរបង្ហាញលក្ខណៈរបស់ព្រះ។
- សកម្មភាព/តួនាទីរបស់មនុស្ស—កំណត់អំពីសកម្មភាព ឬតួនាទីដែលបទគម្ពីរបង្ហាញទៅកាន់មនុស្ស ឬលើកទឹកចិត្តមនុស្សឲ្យធ្វើអ្វីមួយ ឬឲ្យក្លាយជាបែបណាមួយ។
- ពាក្យបង្ហាញពីអារម្មណ៍—តើបទគម្ពីរនេះប្រើប្រាស់ពាក្យពេចន៍ដែលមានថាមពលនៃអារម្មណ៍ដូចប្រើពាក្យពេចន៍ក្នុងន័យជាសាច់ញាតិ (ឪពុក កូន) ឬពាក្យដូចជាមានលក្ខណៈ «អង្វរ» ដែរឬទេ?
- រូបារម្មណ៍នៃបទគម្ពីរ—តើរូបារម្មណ៍ជារួមនៃបទគម្ពីរនេះនិយាយអំពីអ្វី៖ សប្បាយ សោកសៅ លើកទឹកចិត្ត ស្ដីបន្ទោស ឬអ្វីផ្សេងទៀត?
- ការតភ្ជាប់ទៅកថាខណ្ឌ ឬភាគបន្ទាប់—តើបទគម្ពីរនេះមានការតភ្ជាប់ទៅកាន់កថាខណ្ឌដែលមានខាងមុខ និងភាគបន្ទាប់ទៀតយ៉ាងដូចម្ដេច?
- ការផ្លាស់ប្ដូរនៅក្នុងរឿង—តើបទគម្ពីរត្រូវបានប្រើប្រាស់ជាគន្លឹះ ដើម្បីឲ្យយល់ពីការផ្លាស់ប្ដូរនៅក្នុងដំណើររឿងដែរឬទេ?
- ការផ្លាស់ប្ដូរ—តើបទគម្ពីរមានការផ្លាស់ប្ដូរគ្នាទៅវិញទៅមករវាងឈុតឆាកពីរ ឬតួអង្គពីរដែរឬទេ?

(តារាងវិធីសាស្ត្រនេះត្រូវបានចែកចាយមកពី *"Grasping God's Word" by Duvall & Hays*)។

# លក្ខណៈរបស់ព្រះ

ក្នុងចំណោមវិធីសាស្រ្តទាំងអស់ខាងលើ មានវិធីមួយដែលខ្ញុំចូលចិត្ត ហើយខ្ញុំរៀនបានចេញពីការសិក្សាព្រះគម្ពីរគឺការដែលតែងតែស្វែងរកទិដ្ឋភាពនៃលក្ខណៈរបស់ព្រះក្នុងគ្រប់បទគម្ពីរទាំងអស់ដែលខ្ញុំបានសិក្សា និងអាន។

ជាញឹកញាប់ មនុស្សមានទំនោរក្នុងការស្វែងរកខ្លួនឯងនៅក្នុងបទគម្ពីរណាមួយ ឬប្រើប្រាស់បទគម្ពីរណាមួយ ដើម្បីស្វែងយល់បន្ថែមទៀតអំពីខ្លួនឯងជាជាងស្វែងយល់អំពីព្រះមួយអង្គដែលបទគម្ពីរទាំងមូលសរសេរអំពីទ្រង់។



## តើលោកអ្នកមើលឃើញលក្ខណៈរបស់ព្រះអ្វីខ្លះនៅក្នុងបទគម្ពីរនេះ?

ជំនួយ៖ លោកអ្នកអាចប្រើប្រាស់តារាងនៃលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ ដើម្បីជួយលោកអ្នកកំណត់អំពីលក្ខណៈទាំងអស់នេះប្រសិនបើត្រូវការ។

# ការភ្ជាប់ទៅនឹងដំណឹងល្អ

ខ្ញុំស្រឡាញ់ឃ្លាភ្ជាប់នៅក្នុងសៀវភៅ «ដំណើររឿងព្រះយេស៊ូវតាមរយៈព្រះគម្ពីរ» ណាស់ ដែលបានសរសេរថា «រឿងរ៉ាវទាំងអស់និយាយខ្សឹបខ្សៀវពីព្រះនាមទ្រង់»។ ហើយនេះជាការពិតណាស់! របៀបដែលខ្ញុំបានរៀនក្នុងការពិចារណាអំពីការដែលដំណឹងត្រូវបានមានទំនាក់ទំនងក្នុងគ្រប់ផ្នែកទាំងអស់នៃបទគម្ពីរ គឺជាការគិតអំពីដំណឹងល្អទុកដូចជាត្បូងឆ្នៃអញ្ចឹង៖ ត្បូងដែលច្នៃរួចមានជ្រុងផ្សេងៗ ដូចគ្នានឹងដំណឹងល្អដែរ! ហើយវាជាតួនាទីរបស់យើងក្នុងការជីកយកបទគម្ពីរនីមួយៗ ដើម្បីអាចស្វែងរកបានត្បូងដ៏ស្រស់ស្អាតមួយនេះ។

ការសុគត ការបញ្ចុះ និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទនឹងតែងតែជាចំណុចកណ្ដាលនៃថ្មដ៏មានតម្លៃនេះ ជាផ្នែកដែលងាយស្រួលមើលឃើញបំផុត និងចែងចាំងបំផុត។ ប៉ុន្តែ ការចាប់បដិសន្ធិរបស់ព្រះយេស៊ូវ ព្រះជន្ម និងការបង្រៀន ការយាងត្រឡប់ទៅស្ថានសួគ៌ និងការយាងត្រឡប់មកវិញរបស់ព្រះអង្គក៏ជាផ្នែកមួយនៃដំណឹងល្អផងដែរ។



ដូច្នេះ នៅពេលដែលគ្រប់បទគម្ពីរទាំងអស់ទំនងជាមិនបាននិយាយអំពីឈើឆ្កាង មិនថាដោយផ្ទាល់ ឬដោយប្រយោលនោះទេ គឺប្រាកដជាមានអ្វីម៉្យាងដែលអាចជីករកបាន ហើយក៏ចង្អុលបង្ហាញទៅកាន់ព្រះគ្រីស្ទផងដែរ។

សំណួរត្រិះរិះ៖

- នៅក្នុងកណ្ឌគម្ពីរនេះ តើលោកអ្នកមើលឃើញទិដ្ឋភាពអ្វីខ្លះអំពីដំណឹងល្អ?
- តើបទគម្ពីរនេះមានដំណើរការបែបណា? តើបទគម្ពីរនេះត្រាស់ហៅឲ្យលោកអ្នកធ្វើអ្វី?

ជំនឿ ការប្រែចិត្ត ការអត់ទោស ការស្តាប់បង្គាប់

- តើកណ្ឌគម្ពីរនេះមានចែងយ៉ាងច្បាស់អំពីព្រះយេស៊ូវដែរឬទេ?
- តើកណ្ឌគម្ពីរនេះចង្អុលបង្ហាញអំពីព្រះយេស៊ូវដែរឬទេ?
- តើមានទិដ្ឋភាពណាមួយដែលនិយាយអំពី «តំណាង» ដែរឬទេ? (អ័ដាម ព្រះយេស៊ូវតំណាងឲ្យ អ័ដាម ចុងក្រោយ)។
- តើកណ្ឌគម្ពីរនេះមាននិយាយអំពីទំនាយរបស់ព្រះមេស្ស៊ីដែរឬទេ?
- តើកណ្ឌគម្ពីរនេះមានបញ្ជាក់អំពីតម្រូវការរបស់ព្រះមេស្ស៊ីដែរឬទេ?

## ព្រះយេស៊ូវ គឺជាចំណុចស្នូល នៃបទគម្ពីរទាំងមូល!



រួចទ្រង់ក៏ស្រាយន័យសេចក្ដីដែលតម្រូវដល់ទ្រង់ពីក្នុងគម្ពីរទាំងឡាយឲ្យគេស្ដាប់ ចាប់តាំងពីគម្ពីរលោកម៉ូសេ និងគម្ពីរពួកហោរារៀងមក
( លូកា ២៤:២៧)។[4]

# ការអនុវត្ត

ការអានព្រះបន្ទូលដោយមើលពីជីវិតខ្លួនឯងគឺជាសេចក្តីល្បួង ហើយការធ្វើដូច្នេះមិនមែនជាការត្រឹមត្រូវដែលយើងគួរអនុវត្តក្នុងការអានព្រះបន្ទូលឡើយ។

ដ្យាក្រាមខាងក្រោមនេះ អាចជួយឲ្យយើងអាចមើលឃើញច្បាស់អំពីចំណុចអនុវត្ត ដែលមានប្រភពមកពី ឆាលស៏ ស៊ីមៀន ត្រាសធ៍ (The Charles Simeon Trust)៖




មកដល់ចំណុចនេះ លោកអ្នកបានសិក្សាស៊ីជម្រៅ ហើយរៀនបានថា៖

- អ្នកណាជាអ្នកនិពន្ធបទគម្ពីរនេះ
- គាត់សរសេរទៅកាន់អ្នកណា
- អ្នកនិពន្ធកំពុងព្យាយាមប្រាស្រ័យទាក់ទងទៅកាន់អ្នកអានរបស់គាត់អំពីអ្វី (ពួកគេ/បន្ទាប់មក)
- បទគម្ពីរនេះមានទំនាក់ទំនងទៅកាន់ដំណឹងល្អយ៉ាងដូចម្តេច

{ កិច្ចការទាំងនេះបានបញ្ចប់ហើយ ឥឡូវនេះដល់ពេលដែលលោកអ្នកត្រូវអនុវត្តនូវអ្វីដែលខ្លួនបានរៀននៅក្នុងជីវិតរស់នៅផ្ទាល់ខ្លួនហើយ! }

ជាដំបូង ចូរសរសេរចំណុចអនុវត្តជាក់លាក់ណាមួយដែលផ្អែកលើអត្ថបទព្រះគម្ពីរ។

ឥឡូវ នេះគឺជាសំណួរជំនួយបន្ថែមទៀតសម្រាប់ឲ្យលោកអ្នកគិតពិចារណា៖

- ក្នុងបទគម្ពីរនេះ តើមានសេចក្ដីបង្គាប់ណាដែលខ្ញុំត្រូវគោរពស្ដាប់បង្គាប់តាមដែរឬទេ?
- ក្នុងបទគម្ពីរនេះ តើមានអំពើបាបណាមួយដែលខ្ញុំត្រូវគេចចេញដែរឬទេ? តើមានអ្វីមួយជាក់លាក់ដែលខ្ញុំត្រូវប្រែចិត្តចេញដែរឬទេ?
- ក្នុងកណ្ឌគម្ពីរនេះ តើមានអកប្បកិរិយា ឬផ្នត់គំនិតណាមួយដែលខ្ញុំគួរត្រាប់តាមដែរឬទេ?
- តើអ្វីដែលខ្ញុំបានរៀនអំពីព្រះក្នុងកណ្ឌគម្ពីរនេះ អាចផ្លាស់ប្ដូររបៀបដែលខ្ញុំគិត និងរស់នៅយ៉ាងដូចម្ដេច?



- តើអ្វីដែលខ្ញុំបានរៀនអាចផ្លាស់ប្ដូររបៀបដែលខ្ញុំសម្លឹងមើលអំពីស្ថានភាពខ្ញុំជាក់ស្ដែងបានយ៉ាងដូចម្ដេច?
- តើមានសកម្មភាពជាក់ស្ដែងណាមួយដែលខ្ញុំអាចធ្វើបាន ហើយខ្ញុំអាចអនុវត្តភ្លាមៗ បន្ទាប់ពីខ្ញុំបានសិក្សាបទគម្ពីរនេះដែរឬទេ?

# កំណត់ត្រាសិក្សា



Sources


1. "Biblegateway.com: A Searchable Online Bible in over 150 Versions and 50 Languages." n.d. Biblegateway.com. Accessed November 4, 2022. https://www.biblegateway.com.
2. Duvall, J. Scott, and J. Daniel Hays. 2012. Grasping God's Word: A Hands-on Approach to Reading, Interpreting, and Applying the Bible. 3rd ed. Grand Rapids, MI: Zondervan.
3. Life.Church. (2023). YouVersion Bible (Version 10.0) [Mobile app]. App Store. https://www.youversion.com/.
4. ESV Bible: English Standard Version. 2009. Peabody, MA: Hendrickson.
5. Liening, Hallie. 2018. "Three Ways You Might Be Reading Your Bible Wrong." Hallie Writes (blog). March 19, 2018. https://www.halliewrites.com/home/three-ways-you-might-be-reading-your-bible-wrong.
6. Lloyd-Jones, Sally. 2017. The Jesus Storybook Bible: Every Story Whispers His Name. Zonderkidz on Dreamscape Audio.
7. McFadden, Colleen. 2021. "The Charles Simeon Trust Women's Workshop on Biblical Exposition." October 7.

Works of Willing Hands

Proverbs 31:13